# ព្រះរាជាណាចក្រកម្ពុជា

ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ង់ **ជាតិ សាសនា ព្រះមហាក្សត្រ**

KOBE JAPANESE RESTAURANT

# កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល៥២ថ្ងៃ គឺចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

ថ្ងៃចន្ទ ទី១៥កើត ខែពិសាខ ឆ្នាំឆ្លូវត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនិងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ង់ មានអាសយដ្ឋានស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបដែលមានចំនួនកម្មករនិយោជិតសរុប ចំនួន៣៩នាក់ កម្មករនិយោជិតជាស្ត្រីមានចំនួន៣៥នាក់ មាននាយកឈ្មោះ គឹម វិបុល ជនជាតិខ្មែរ ជាតំណាងក្រុមហ៊ុនកូបេ យៃភែននីស រ៉េស្តូរ៉ង់ បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករ និយោជិត រយៈពេល៥២ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក គឹម វិបុល ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់មូលហេតុដោយសារតែបញ្ហាការផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ធ្វើអោយភ្ញៀវមានការធ្លាក់ចុះយ៉ាងខ្លាំង ដូចនេះក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ង់ និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៣៧នាក់រយៈ៥២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

២-ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនិងទទួលបានប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាល ៨០ដុល្លារក្នុង៥២ថ្ងៃ ។

ខេត្តសៀមរាប,ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

បានឃើញ និងឯកភាព

តំណាងក្រុមហ៊ុន

តំណាងកម្មករនិយោជិត

ស៊ុំ គឹមសាន

សុង ម៉ី